ឆ្នាំទី៥ លេខ ៥៩ ខែវិច្ឆិកា ឆ្នាំ២០១៧

# ព្រឹត្តិបត្រ
# កៅស៊ូធម្មជាតិ
# Natural Rubber Bulletin

ផ្សាយចេញពី អគ្គនាយកដ្ឋានកៅស៊ូ



















ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០

# មាតិកា


| | ទំព័រ |
|---|---|
| ❖ បទវិចារណកថា | ១ |
| **ព័ត៌មានក្នុងប្រទេស** | |
| ❖ ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បំពេញទស្សនកិច្ចសម្ព័ន្ធកៅស៊ូវៀតណាម (VRG) នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម | ៣ |
| ❖ កិច្ចប្រជុំពិនិត្យនិងកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពី កៅស៊ូ | ៧ |
| ❖ ការបើកមហាសន្និបាតកំណើតដំបូងរបស់សហគមន៍កសិកម្មកៅស៊ូគ្រួសារ ស្រុកសំឡូត ខេត្តបាត់ដំបង | ៧ |
| ❖ វគ្គផ្សព្វផ្សាយនិបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS ដល់សហគមន៍កៅស៊ូគ្រួសារ | ១១ |
| កិច្ចសហប្រតិបត្តិការរវាងអគ្គនាយកដ្ឋានកៅស៊ូជាមួយនឹងក្រុមហ៊ុន Anhui Easy Business | ១៤ |
| ❖ របាយការណ៍ស្តីពី ស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត | ១៦ |
| **ព័ត៌មានអន្តរជាតិ** | |
| ❖ ប្រទេសផលិតកៅស៊ូអាស៊ានធំៗកាត់បន្ថយការនាំចេញនៅខែក្រោយ បន្ទាប់ពីតម្លៃបានធ្លាក់ចុះ | ២១ |
| ❖ រដ្ឋសាបា នឹងផ្តួចផ្តើមដោយប្រើប្រាស់កៅស៊ូធម្មជាតិ ដើម្បីដោះស្រាយតម្លៃកៅស៊ូធ្លាក់ចុះ | ២២ |
| **ទំព័រស្រាវជ្រាវ** | |
| ❖ នីតិវិធីបង្កើតមណ្ឌលកែច្នៃ ជ័រកៅស៊ូសន្លឹក USS | ២៣ |
| **តម្លៃនិងស្ថិតិកៅស៊ូធម្មជាតិតាមបណ្តាប្រទេសនានា** | |
| ❖ តារាងទី១៖ តម្លៃប្រមូលទិញជ័រកៅស៊ូពីកសិករកៅស៊ូគ្រួសារខែវិច្ឆិកា ឆ្នាំ២០១៧ | ២៨ |
| ❖ តារាងទី២៖ ស្ថានភាពធុរកិច្ចផលិតផលជ័រកៅស៊ូស្ងួតប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ | ២៩ |
| ❖ តារាងទី៣៖ តម្លៃកៅស៊ូនៅទីផ្សារប្រទេសថៃ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ | ៣០ |
| ❖ តារាងទី៤៖ តម្លៃកៅស៊ូស្តង់ដាម៉ាឡេស៊ី SMR/FOB ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ | ៣១ |
| ❖ តារាងទី៥៖ តម្លៃកៅស៊ូស្តង់ដាវៀតណាម SVR/FOB ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ | ៣២ |
| ❖ តារាងទី៦៖ តម្លៃកៅស៊ូធម្មជាតិចេញដោយ Association of Natural Rubber Producing Countries ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ | ៣៣ |
| ❖ តារាងទី៧៖ តម្លៃកៅស៊ូសន្លឹកលេខ៣ (RSS3) នៅលើទីផ្សារហ៊ុន TOCOM | ៣៤ |
| ❖ តារាងទី៨៖ តម្លៃកៅស៊ូសន្លឹកលេខ៣ (RSS3) នៅលើទីផ្សារហ៊ុនសៀងហៃ | ៣៥ |
| **ក្រាហ្វិក** | |
| ❖ ក្រាហ្វិកទី១ ៖ ឥទ្ធិពលតម្លៃកៅស៊ូ RSS-3 ទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនសៀងហៃ និងតម្លៃកៅស៊ូ SMR-20 នៅលើទីផ្សារទិញលក់ភ្លាមៗ | ៣៦ |
| ❖ ក្រាហ្វិកទី២ ៖ ឥទ្ធិពលនៃតម្លៃប្រេងឆៅទៅលើតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យានៅទីផ្សារសៀងហៃ | ៣៧ |
| ❖ ក្រាហ្វិកទី៣ ៖ ឥទ្ធិពលប្រាក់យ័នចិនទៅលើតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យានៅទីផ្សារសៀងហៃ | ៣៨ |
| ❖ ក្រាហ្វិកទី៤៖ ឥទ្ធិពលនៃតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនតូក្យូទៅលើតម្លៃកៅស៊ូ SMR-20 នៅលើទីផ្សារទិញលក់ភ្លាមៗ | ៣៨ |
| ❖ ក្រាហ្វិកទី៥៖ ឥទ្ធិពលប្រាក់យ៉េនទៅលើតម្លៃកៅស៊ូទិញលក់តាមកិច្ចសន្យានៅទីផ្សារហ៊ុនតូក្យូ | ៣៩ |


អបអរសាទរខួបអនុស្សាវរីយ៍លើកទី៦៤
ទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា (១៩៥៣-២០១៧)

# បទវិចារណកថា

*ប្រិយមិត្តទាំងអស់ជាទីមេត្រី!*

ស្ថានភាពផលិតកម្ម និងធុរកិច្ចកៅស៊ូធម្មជាតិកម្ពុជា នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ បានបង្ហាញថា បរិមាណផលិតសរុបប្រចាំខែវិច្ឆិកា មានចំនួន ២៣ ០២៨តោន បានកើនចំនួន ៤ ៩៧៧តោន (=+២៨%) ធៀបនឹងខែមុននិងបានកើនឡើងចំនួន ៦ ០១២តោន (=+៣៥%) បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦។ បើគិតក្នុងរយៈពេល១១ខែ ឆ្នាំ២០១៧ បរិមាណផលិតសរុបមានចំនួន ៥៩ ៨០៥តោន បានកើនឡើង ៤២ ៦៨២តោន (=+៣៦%) បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦។ បរិមាណបញ្ចេញលក់ក្នុងខែវិច្ឆិកា មានចំនួន ២២ ១៤៦តោន បានកើនឡើងចំនួន ៦ ៣៩១តោន (=+៤១%) ធៀបនឹងខែមុន និងបានកើនឡើង ៥ ៦៥៤តោន (=+៣៤%) បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦។ បរិមាណបញ្ចេញលក់សរុបក្នុងរយៈពេល១១ខែ មានចំនួន ១៥២ ៩៦២តោន បានកើនឡើងចំនួន ៣៦ ៦១៣តោន (=+៣១%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦។ បរិមាណសន្និធិចុងខែវិច្ឆិកា ឆ្នាំ២០១៧ មានចំនួន ១៤ ៦៤២តោន។ តម្លៃលក់ជាមធ្យមក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ស្មើនឹង ១ ៤៥៩US$/តោន បានថយចុះ ៦៣US$/តោន (= - ៤,១២%) ធៀបនឹងខែមុន និងបានថយចុះ ២៩US$/តោន (= -២%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦។ តម្លៃលក់មធ្យមក្នុងរយៈពេល១១ខែ ឆ្នាំ២០១៧ ស្មើនឹង ១ ៦២៥US$/តោន កើនឡើង ៤៥២US$/តោន (= +៣៨%) ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៦។

ចំពោះស្ថានភាពទិញជ័រកៅស៊ូគ្រួសារតាមតំបន់នានាប្រចាំខែវិច្ឆិកានេះ មានតម្លៃមធ្យម ៤៤៤៥៛/គ.ក្រ (=១,១០US$/គ.ក្រ) សម្រាប់ជ័រស្ងួត និង ២០៥៥៛/គ.ក្រ (=០,៥១US$/គ.ក្រ) សម្រាប់ជ័រកក។ ពិនិត្យជារួម តម្លៃទិញជ័រកៅស៊ូគ្រួសារតាមតំបន់នានាមានការប្រែប្រួលតិចតួចបំផុត ធៀបនឹងសប្តាហ៍ទី៤នៃខែតុលាកន្លងទៅ ប៉ុន្តែ តម្លៃនេះបានរអិលធ្លាក់ប្រមាណ ២០៛/គ.ក្រ នៅតាមតំបន់ខ្លះ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧នេះ។

យោងរបាយការណ៍ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ របស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ (ANRPC) បានបង្ហាញថា បរិមាណផលិតផលកៅស៊ូធម្មជាតិពិភពលោកក្នុងរយៈពេល១១ខែ មានចំនួន ១១,៦៧៦លានតោន (=+៤,៧%) រីឯបរិមាណប្រើប្រាស់វិញមានចំនួន១១,៨០៤លានតោន (=+១,២%) គឺមានតម្រូវការលើសការផ្គត់ផ្គង់ប្រហែល ១២៨ ០០០តោន។ នៅក្នុងខែវិច្ឆិកានេះផងដែរ តំបន់ភាគខាងកណ្តាលនិងភាគខាងត្បូងនៃប្រទេសវៀតណាមបានទទួលរងព្យុះទីហ្វុងឈ្មោះ**ដំរី** ដែលបណ្តាលឲ្យខូចខាតចម្ការដំណាំអស់ ៤០ ០០០ ហ.ត ដែលក្នុងនោះក៏មានចម្ការកៅស៊ូផងដែរ។ គ្រោះធម្មជាតិនេះក៏បានវាយប្រហារតំបន់ដាំដុះកៅស៊ូសំខាន់ៗមួយចំនួនទៀត ដូចជានៅភាគខាងត្បូងប្រទេសថៃដែលកំពុងទទួលរង

ជំនន់ទឹកភ្លៀងដ៏លឿនរហ័ស ហើយបណ្ដាស្រុកជាច្រើននៅក្នុងខេត្តមួយចំនួនត្រូវបានប្រកាសថាជាតំបន់នឹងត្រូវទទួលរងគ្រោះធម្មជាតិនេះ។

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧នេះ តម្លៃកៅស៊ូធម្មជាតិនៅគ្រប់ទីផ្សារទិញ-លក់ទូទាត់ភ្លាមៗ (Physical Market) និងទីផ្សារទិញលក់តាមកិច្ចសន្យា (Future Market) មាននិន្នាការនៅទ្រឹងនឹងនំនៅឡើយ ទោះបីជាម្លៃប្រេងឆៅមាននិន្នាការងើបឡើងបន្តិចក៏ដោយ នៅក្នុងកំឡុងខែវិច្ឆិកា ឆ្នាំ២០១៧នេះ។

ក្រុមការងារព្រឹត្តិបត្រកៅស៊ូធម្មជាតិនៃអគ្គនាយកដ្ឋានកៅស៊ូ នឹងនៅតែបន្តយកចិត្តទុកដាក់តាមដានពីគ្រប់មជ្ឈដ្ឋានប្រភពព័ត៌មាន ដើម្បីផ្ដល់ជូនខ្លឹមសារ និងរូបភាពកាន់តែច្បាស់ថែមទៀត អំពីស្ថានភាពវិវឌ្ឍនិន្នាការទីផ្សារ និងទស្សនវិស័យនៃឧស្សាហកម្មកៅស៊ូធម្មជាតិ សម្រាប់រយៈពេលខ្លី មធ្យម និងវែង ទាំងក្នុងក្របខណ្ឌជាតិ តំបន់ និងពិភពលោក។ ជាមួយគ្នានេះ ក្រុមការងារយើងខ្ញុំ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់សម្ដេច ទ្រង់ ឯកឧត្ដម លោកជំទាវ លោក/អ្នកឧកញ៉ា និងមិត្តអ្នកអានទាំងអស់ និងរង់ចាំទទួលមតិរិះគន់ស្ថាបនាពីគ្រប់មជ្ឈដ្ឋាន ដើម្បីកែលម្អព្រឹត្តិបត្រនេះ ឲ្យកាន់តែមានគុណភាពប្រសើរឡើងថែមទៀត។

# ព័ត៌មានក្នុងប្រទេស

## ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បំពេញទស្សនកិច្ចសម្ព័ន្ធកៅស៊ូ វៀតណាម (VRG) នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម

តបតាមការអញ្ជើញរបស់សម្ព័ន្ធកៅស៊ូវៀតណាម (VRG) ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបំពេញទស្សនកិច្ចសម្ព័ន្ធកៅស៊ូវៀតណាម (VRG) នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ចាប់ពីថ្ងៃទី២-៤ ខែវិច្ឆិកា ឆ្នាំ២០១៧។ លោក **ឃុន ភក្ដា** អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ រួមនឹងថ្នាក់ដឹកនាំអង្គភាពជំនាញក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន ០៨រូប បានចូលរួមអមដំណើរឯកឧត្តមរដ្ឋមន្ត្រី នៅក្នុងដំណើរទស្សនកិច្ចនេះ។

ដំណើរបំពេញទស្សនកិច្ចនេះបានប្រព្រឹត្តទៅតាមកម្មវិធីដូចខាងក្រោម៖

| កាលបរិច្ឆេទ | របៀបវារៈ |
|---|---|
| ថ្ងៃទី២ វិច្ឆិកា | - ចេញដំណើរពីទីក្រុងភ្នំពេញ ឆ្ពោះទៅកាន់ទីក្រុងហូជិមីញ |
| ថ្ងៃទី៣ វិច្ឆិកា | - ដំណើរទស្សនកិច្ចពិនិត្យរោងចក្រកែច្នៃជ័រកៅស៊ូ និងចម្ការកៅស៊ូ នៅក្រុមហ៊ុនយ៉ូវទៀង<br>- កិច្ចប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំនៅក្រុមហ៊ុនយ៉ូវទៀង<br>- ដំណើរទស្សនកិច្ចពិនិត្យរោងចក្រកែច្នៃផលិតផលចំណីអាហារពីគ្រាប់ស្វាយចន្ទីនៅក្រុមហ៊ុន Dan - D - PAK |
| ថ្ងៃទី៤ វិច្ឆិកា | - កិច្ចប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំសម្ព័ន្ធកៅស៊ូវៀតណាម (VRG)<br>- ដំណើរវិលត្រឡប់មកទីក្រុងភ្នំពេញវិញ |

ចំពោះសកម្មភាព លទ្ធផល និងសេចក្តីសន្និដ្ឋាន ដែលទទួលបានពីដំណើរទស្សនកិច្ចនេះ មានដូចខាងក្រោម៖

### ១. ថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៧

គណៈប្រតិភូដែលដឹកនាំដោយ ឯកឧត្តមរដ្ឋមន្ត្រី បានចេញដំណើរពីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ឆ្ពោះទៅកាន់អាកាសយានដ្ឋាន Tan San Nhat ទីក្រុងហូជីមិញ ដោយមានការអញ្ជើញចូលរួមជូនដំណើរពីឯកឧត្តមលោកជំទាវជា រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងថ្នាក់ដឹកនាំនាយកដ្ឋានជំនាញឱវាទក្រសួងផងដែរ។

បន្ទាប់មក គណៈប្រតិភូដែលដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រី បានអញ្ជើញដល់អាកាសយានដ្ឋាន Tan San Nhat ទីក្រុងហូជីមីញ ដោយមានការអញ្ជើញទទួលបដិសណ្ឋារកិច្ចពីថ្នាក់ដឹកនាំនៃសម្ព័ន្ធ

កៅស៊ូវៀតណាម (VRG)។ បន្ទាប់មក គណៈប្រតិភូទាំងអស់បានស្នាក់នៅសណ្ឋាគារ Tan San Nhat ។

## ២. ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៧

គណៈប្រតិភូបានចុះពិនិត្យរោងចក្រកែច្នៃទឹកជ័រកៅស៊ូខាប់ ជ័រកៅស៊ូដុំ និងចម្ការកៅស៊ូនៅក្រុមហ៊ុនយ៉ូវទៀង។ នៅក្នុងឱកាសនោះ ឯកឧត្តមរដ្ឋមន្ត្រី និងប្រតិភូអមដំណើរបានសិក្សាស្វែងយល់អំពីការងារបច្ចេកទេស ការងារគ្រប់គ្រង ប្រាក់បៀវត្ស កម្រិតជីវភាពរស់នៅរបស់កម្មករបម្រើការងារក្នុងវិស័យកៅស៊ូ បញ្ហាកម្លាំងពលកម្មនិងបញ្ហាប្រឈមផ្សេងៗផងដែរ។

គណៈប្រតិភូបានជួបប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំនិងបុគ្គលិកកម្មករនៅមន្ទីរក្រុមហ៊ុនយ៉ូវទៀង។ បន្ទាប់ពីមតិស្វាគមនិងណែនាំសមាសភាពប្រតិភូរៀងៗខ្លួនរួចមក តំណាងក្រុមហ៊ុនបានជម្រាបជូនថា៖ ក្រុមហ៊ុនយ៉ូវទៀង បានចាប់ផ្តើមនៅឆ្នាំ១៩៨១ ដែលមានផ្ទៃដីដាំកៅស៊ូសរុបចំនួន ២៨ ៥៩៤,៨៧ហ.ត (កំពុងចៀរជ័រចំនួន ១៨ ២៨០,៩៧ ហ.ត)។ ក្នុងឆ្នាំ២០១៦ កន្លងទៅផលិតបានចំនួន ៣៥ ០០០តោន និងឆ្នាំ២០១៧ នឹងសម្រេចបាន ៣៥ ៣០០តោន និងឆ្នាំ២០២០ បាន ៣៨ ៣០០ តោន។ ក្រុមហ៊ុនមានរោងចក្រកែច្នៃកៅស៊ូដុំចំនួន ០៣កន្លែង ដែលមានសមត្ថភាពផលិតសរុបចំនួន ៤០ ០០០តោន/ឆ្នាំ និងរោងចក្រកែច្នៃទឹកជ័រខាប់ ១ កន្លែងដែលមានសមត្ថភាពផលិតចំនួន ៧ ០០០តោន/ឆ្នាំ។ ផលិតផលសម្រេចបានសម្រាប់ប្រើប្រាស់ក្នុងស្រុកនិងនាំចេញទៅ៤០ប្រទេស ដោយទទួលបានប្រាក់ចំណូលពី ៩៥-១០០លាន$/ឆ្នាំ (ចំណេញពី ២៥-៣០លាន$/ឆ្នាំ និងបង់ចូលថវិកាជាតិពី ៧-១០ លាន$/ឆ្នាំ)។ បុគ្គលិកកម្មករសរុបមានចំនួនពី ៦ ៥០០ ទៅ ១១ ០០០នាក់ ដោយទទួលប្រាក់ខែជាមធ្យម ៣០០$/ខែ។ ក្រៅពីចម្ការកៅស៊ូ ក្រុមហ៊ុនវិនិយោគលើតំបន់សេដ្ឋកិច្ចពិសេស ការកែច្នៃឈើកៅស៊ូ និងផលិតផលកសិកម្មផងដែរ។ នៅកម្ពុជា ក្រុមហ៊ុនមានបុត្រសម្ព័ន្ធពីរគឺ ក្រុមហ៊ុនយ៉ូវទៀងកម្ពុជា និងក្រុមហ៊ុនយ៉ូវទៀងក្រចេះ ដែលមានផ្ទៃដីសរុបចំនួន ៤ ៣០០ ហ.ត។ នៅឆ្នាំ២០១៨ ត្រៀមបើកចៀរជ័រចំនួន ៣០០ហ.ត នឹងបើកទាំងស្រុងនៅឆ្នាំ២០២២ ចំនួន ៤ ២២០ហ.ត ដែលនឹងត្រូវការកម្លាំងពលកម្មចំនួន ១ ៥០០នាក់ (បច្ចុប្បន្ន៥០០នាក់)។

ឯកឧត្តមរដ្ឋមន្ត្រី បានសំដែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលការងាររបស់ក្រុមហ៊ុន ហើយឯកឧត្តមសង្ឃឹមថា ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅកម្ពុជានឹងទទួលបានជោគជ័យដូចនេះដែរ។ ឯកឧត្តមសន្យានឹងចូលរួមសម្ពោធរោងចក្រកែច្នៃជ័រកៅស៊ូរបស់ក្រុមហ៊ុននៅកម្ពុជានៅពេលខាងមុខ។

គណៈប្រតិភូ បានជួបប្រជុំពិភាក្សាការងារ និងពិនិត្យរោងចក្រកែច្នៃផលិតផលចំណីអាហារពីគ្រាប់ស្វាយចន្ទី នៅក្រុមហ៊ុន Dan-D-PAK ដែលផលិតសម្រាប់ផ្គត់ផ្គង់ការនាំចេញទៅបរទេស ជាពិសេសសហគមអឺរ៉ុប។ ឯកឧត្តមរដ្ឋមន្ត្រីសំដែងការគាំទ្រយ៉ាងពេញទំហឹងចំពោះគម្រោងវិនិយោគបង្កើតរោង-ចក្រកែច្នៃគ្រាប់ស្វាយចន្ទីនៅកម្ពុជា ដែលមានទឹកប្រាក់ចំនួន២០លាន$។


ឯកឧត្តមរដ្ឋមន្ត្រី បានធ្វើទស្សនកិច្ចចម្ការកៅស៊ូ នៅក្រុមហ៊ុនយ៉ូវទៀង

## ៣. ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១៧

ប្រតិភូ បានជួបប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំនៃសម្ព័ន្ធកៅស៊ូវៀតណាម (VRG) នៅទីស្នាក់ការធំក្នុងទីក្រុងហូជីមិញ ដែលដឹកនាំដោយលោក Tan Ngoc Tuan ប្រធាន VRG និងលោក Vo Sy Luc នាយកប្រតិបត្តិ VRG។ បន្ទាប់ពីមតិស្វាគមន៍ និងណែនាំសមាសភាពប្រតិភូរៀងៗខ្លួន និងស្តាប់របាយការណ៍សង្ខេបអំពីសកម្មភាពនិងលទ្ធផលការងាររបស់ VRG រួចមក ឯកឧត្តមរដ្ឋមន្ត្រីបានឆ្លើយបំភ្លឺ និងផ្តល់ដំណោះស្រាយចំពោះបញ្ហានានា ដែលភាគីវៀតណាមបានលើកឡើងមានដូចខាងក្រោម៖

- **បញ្ហាជួយអន្តរាគមបញ្ចប់នីតិវិធីបែបបទដីសម្បទាន ការចុះបញ្ជីដីរដ្ឋ និងការវាយតម្លៃ EIA ៖** សូមទទួលយកនិងជំរុញអង្គភាពជំនាញពាក់ព័ន្ធពន្លឿនការងារនេះឲ្យបានឆាប់ ដើម្បីឈានទៅចុះកិច្ចសន្យា និងកែប្រែផែនការមេឡើងវិញ។ ប៉ុន្តែ បញ្ហា Master plan នេះ គួរក្រុមហ៊ុនជាអ្នករៀបចំឲ្យហើយ រួចដាក់ស្នើសុំមកក្រសួង ទើបក្រសួងមានចំណាត់ការតាមក្រោយ
- **បញ្ហាសូមពិនិត្យកែសម្រួលឡើងវិញលើការយកពន្ធនាំចេញជ័រកៅស៊ូ៖** ក្រសួងនឹងលើកយកបញ្ហានេះទៅពិភាក្សាជាមួយក្រសួងពាក់ព័ន្ធ ជាពិសេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងមានការសម្រេចពីប្រមុខរាជរដ្ឋាភិបាល។ នៅក្នុងខែធ្នូខាងមុខ ក្រសួងនឹងរៀបចំវេទិកាសាធារណៈមួយដើម្បីប្រមូលធាតុចូលពីភាគីពាក់ព័ន្ធ និងរិះរកដំណោះស្រាយឲ្យបានសមស្រប
- **បញ្ហាសូមជួយផ្សព្វផ្សាយដល់ប្រជាពលរដ្ឋជនជាតិភាគតិច និងសូមបង្វែរជនជាតិវៀត-ណាមនៅតំបន់បឹងទន្លេសាបឲ្យចូលមកធ្វើជាកម្លាំងពលកម្មក្នុងការងារកៅស៊ូ៖** ក្រសួងទទួលយក និងជំរុញការងារនេះ ជាពិសេសសូមគាំទ្រនិងជួយសម្របសម្រួលគ្រប់បែបយ៉ាងចំពោះគំនិតផ្តួចផ្តើមបង្វែរជនជាតិវៀត-ណាមនៅតំបន់បឹងទន្លេសាបឲ្យចូលមកធ្វើជាកម្លាំងពលកម្មក្នុងការងារកៅស៊ូ ដែលជាការងារល្អប្រសើរនិងជួយសម្រាលការបំពុលបរិយាកាសតំបន់បឹងទន្លេសាប។ ប៉ុន្តែ កិច្ចការនេះត្រូវមានគោលនយោបាយសម្របសម្រួលយន្តការនិងដំណោះស្រាយសមស្រប និងត្រូវពិនិត្យពិភាក្សាឲ្យបានហ្មត់ចត់ទើបអាចអនុវត្តបានស្របតាមច្បាប់របស់កម្ពុជា

❖ **បញ្ហាសូមកូតានាំចូលកម្លាំងពលកម្មបម្រើក្នុងវិស័យកៅស៊ូ៖** ក្រសួងនឹងសិក្សាលម្អិតលើបញ្ហានេះ ជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីឲ្យស្របតាមច្បាប់កម្ពុជា

❖ **បញ្ហាសូមជួយសម្របសម្រួលឲ្យមានការផ្តល់ CO នៅត្រឹមមន្ទីរពាណិជ្ជកម្មខេត្ត៖** កិច្ចការនេះ រាជរដ្ឋាភិបាលបាននិងកំពុងរៀបចំធ្វើប្រតិភូកម្មរួចហើយ

❖ **បញ្ហាសូមបញ្ចូលក្រុមហ៊ុនបុត្រសម្ព័ន្ធទាំង២របស់ក្រុមហ៊ុនយ៉ូវទៀងនៅកម្ពុជា មកជាក្រុមហ៊ុនតែមួយវិញ (ដោយសារផ្ទៃដីសល់ទំហំតូច)៖** សូមទទួលយកនិងសូមក្រុមហ៊ុនដាក់សំណើរមកក្រសួង

❖ **បញ្ហាសូមផ្ទៃដីបន្ថែមដើម្បីសង់លំនៅដ្ឋានជូនកម្មករ៖** សូមក្រុមហ៊ុនគួរគិតពិចារណាលើការប្រើប្រាស់ដីក្នុងវង្វង់សម្បទានរបស់ខ្លួន។ ការសុំដីបន្ថែមមានការលំបាកស្មុគ្រស្មាញច្រើន ហើយរាជរដ្ឋាភិបាលបានបិទបញ្ចប់ការផ្តល់ដីរួចទៅហើយ ប៉ុន្តែ មានដំណោះស្រាយអាចសហការជាមួយអាជ្ញាធរខេត្តតាមរយៈយន្តការដីសម្បទានសង្គមកិច្ច។ កាលណាមានសំណើមក ក្រសួងនឹងសម្របសម្រួលដោះស្រាយជូនសម្រាប់សាងសង់លំនៅដ្ឋានកម្មករ

❖ **បញ្ហាពង្រឹងកិច្ចសហប្រតិបត្តិការឡើងវិញរវាងអគ្គនាយកដ្ឋានកៅស៊ូនិងសម្ព័ន្ធកៅស៊ូវៀត-ណាម៖** សូមស្វាគមន៍និងសូមឲ្យអគ្គនាយកដ្ឋានកៅស៊ូទទួលអនុវត្តកិច្ចការងារនេះ ដោយត្រូវធ្វើបច្ចុប្បន្នភាព MOU ឡើងវិញ និងជំរុញកិច្ចសហការគ្នាឲ្យបានល្អប្រសើរ

❖ **បញ្ហាសូមឲ្យក្រុមហ៊ុនវៀតណាមវិនិយោគដំណាំ កៅស៊ូនៅកម្ពុជាបានចូលជាសមាជិកនៃសមាគមអភិវឌ្ឍកៅស៊ូកម្ពុជា (ARDC)៖** សូមអគ្គនាយកដ្ឋានកៅស៊ូសម្រសម្រួលលើកិច្ចការងារនេះ។ ទន្ទឹមនឹងនេះ ឯកឧត្តមរដ្ឋមន្ត្រីក៏បានលើកសំណូមពរសូមឲ្យមានការជួបពិភាក្សាគ្នារវាងភាគីទាំងពីរ រៀងរាល់១ខែ/ម្តង ឬ៣ខែ/ម្តង តាមការជាក់ស្តែង ដើម្បីរួមគ្នាដោះស្រាយបញ្ហាផ្សេងៗបានទាន់ពេល។



*ប្រតិភូកម្ពុជា បានជួបប្រជុំពិភាក្សាការងារជាមួយថ្នាក់ដឹកនាំនៃសម្ព័ន្ធកៅស៊ូវៀតណាម (VRG) នៅទីស្នាក់ការជំក្នុងទីក្រុងហូជីមិញ*

## ៤. សន្និដ្ឋាន

ដំណើរទស្សនកិច្ច ដែលដឹកនាំដោយឯកឧត្តមរដ្ឋមន្ត្រី ទៅកាន់សម្ព័ន្ធកៅស៊ូវៀតណាម (VRG) ទទួលបានលទ្ធផលជោគជ័យ ប្រកបដោយស្មារតីយោគយល់ និងសហការល្អ ជាពិសេសសម្រាប់

អគ្គនាយដ្ឋានកៅស៊ូ ដែលឯកឧត្តមរដ្ឋមន្ត្រីបានប្រគល់ភារកិច្ចសំខាន់ចំនួន៣ ត្រូវអនុវត្តនាពេលខាងមុខ៖

១). សិក្សាអំពីកំណើនប្រាក់ខែកម្មករធៀបទៅនឹងនិន្នាការតម្លៃកៅស៊ូ ដែលអាចនិងធ្វើឲ្យប៉ះពាល់ដល់កង្វះកម្លាំងពលកម្មក្នុងអនាគត

២). ពង្រឹងកិច្ចសហប្រតិបត្តិការឡើងវិញរវាងអគ្គនាយកដ្ឋានកៅស៊ូនិងសម្ព័ន្ធកៅស៊ូវៀតណាម តាមរយៈរៀបចំបច្ចុប្បន្នភាព MOU ឡើងវិញ និងជំរុញកិច្ចសហការគ្នាឲ្យបានល្អប្រសើរ

៣). សម្រសម្រួលជាមួយសមាគមអភិវឌ្ឍកៅស៊ូកម្ពុជា (ARDC) ដើម្បីឲ្យក្រុមហ៊ុនវៀតណាមវិនិយោគដំណាំកៅស៊ូនៅកម្ពុជាបានចូលជាសមាជិក។

## កិច្ចប្រជុំពិនិត្យ និងកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពី កៅស៊ូ

កាលពីថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅអគ្គនាយកដ្ឋានកៅស៊ូ មានបើកកិច្ចប្រជុំពិភាក្សា និងកែសម្រួលឡើងវិញលើសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូក្រោមអធិបតីភាព ឯកឧត្តម **ម៉ុល សុផា** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ។




*ឯកឧត្តម **ម៉ុល សុផា** ជាគណៈអធិបតីនៅក្នុងកិច្ចប្រជុំពិភាក្សានិងកែសម្រួលឡើងវិញលើសេចក្តីព្រាងច្បាប់ ស្តីពីកៅស៊ូ*

ជាកិច្ចចាប់ផ្តើមលោក **លួន សុខខេន** អនុ-ប្រធាននាយកដ្ឋានរដ្ឋបាលនិងនីតិកម្ម បានសម្តែងនូវមតិស្វាគមន៍ចំពោះសមាជិកនិងក្រុមការងារទាំងអស់ដែលបានចូលរួមប្រជុំ និងបានបញ្ជាក់ពីគោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីធ្វើការកែសម្រួលនូវចំណុចមួយចំនួននៅក្នុងជំពូកទី៤ នៃសេចក្តីព្រាងច្បាប់ស្តីពី កៅស៊ូបន្ត។

នៅក្នុងឱកាសនោះ ឯកឧត្តមប្រតិភូ ក៏បានមានប្រសាសន៍ថា ការកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូនេះ គួរធ្វើការកែសម្រួលអោយបានត្រឹមត្រូវ បើមិនមានភាពច្បាស់លាស់ទេក្រុមការងាររៀបចំសេចក្តីព្រៀងច្បាប់នេះ ត្រូវទំនាក់ទំនងជាមួយអ្នកដែលបានផ្តល់ជាមតិយោលបល់ក្នុងអង្គប្រជុំ ឬឯកឧត្តមប្រធានអង្គប្រជុំដោយផ្ទាល់ ដើម្បីជំរុញការងារនេះឲ្យបានលឿនប្រកបដោយប្រសិទ្ធិភាពខ្ពស់។

ជាលទ្ធផល អង្គប្រជុំបានឯកភាពនិងសម្រេចទទួលយកការកែតម្រូវលើសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូចាប់ពីមាត្រាទី២៥ ដល់មាត្រាទី៣៤ នៅក្នុងជំពូក

ទី៤ ដើម្បីដាក់ប្រជុំបន្តនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ជាចុងបញ្ចប់ ឯកឧត្តមប្រតិភូ បានថ្លែងអំណរគុណចំពោះអស់លោក លោកស្រី ជាសមាជិកទាំងអស់ ដែលបានចូលរួមនិងបានផ្តល់ជាមតិល្អៗ ក្នុងកិច្ចប្រជុំកែសម្រួលសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ។

## ការបើកមហាសន្និបាតកំណើតដំបូងរបស់សហគមន៍កសិកម្មកៅស៊ូគ្រួសារ ស្រុកសំឡូត ខេត្តបាត់ដំបង

ចាប់ពីថ្ងៃទី២៦-២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ នាយកដ្ឋានអភិវឌ្ឍន៍កៅស៊ូ បានចុះបំពេញបេសកកម្មទៅស្រុកសំឡូត ខេត្តបាត់ដំបង ដើម្បីបង្កើតសហគមន៍កសិករកៅស៊ូគ្រួសារក្នុងគោលបំណង៖ ១)-លើកកម្ពស់ស្ថានភាពសេដ្ឋកិច្ចសង្គម និងវប្បធម៌របស់កសិករជាសមាជិកសហគមន៍ និង ២)-ចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទនិងសេដ្ឋកិច្ចសហគមន៍ជនបទ និងសេដ្ឋកិច្ចជាតិ។

មហាសន្និបាតនេះ ត្រូវបានរៀបចំឡើងនៅសាលប្រជុំផ្ទះសំណាក់ទេសចរណ៍ស្រុកសំឡូតក្រោមអធិបតីភាព លោកបណ្ឌិត **អួន សុវណ្ណ** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ និងមានការអញ្ជើញចូលរួមពីលោក **អ៊ិន សុវណ្ណមុនី** អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង និងលោក **ឈឿត សុធា** អភិបាលរង នៃគណៈអភិបាលស្រុកសំឡូត និងមានកសិករកៅស៊ូគ្រួសារចូលរួមសរុបចំនួន ៤៨នាក់ ក្នុងនោះស្រី ១១នាក់។

ជាកិច្ចចាប់ផ្តើម លោកអនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង បានថ្លែងអំណរគុណដល់ក្រុមការងារអគ្គនាយកដ្ឋានកៅស៊ូ ដែលបានយកចិត្តទុកដាក់ជួយជ្រោមជ្រែង និងសហការជាមួយមន្ត្រីជំនាញរបស់មន្ទីរកសិកម្មខេត្ត ក្នុងការចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារនេះឡើង។ លោកក៏បានសំណូមពរដល់កសិករកៅស៊ូគ្រួសារ ដែលចូលរួមទាំងអស់គួរតែចូលរួមជាសមាជិកសហគមន៍កសិកម្មកៅស៊ូគ្រួសារឲ្យបានគ្រប់គ្នា ដើម្បីទទួលបានអត្ថប្រយោជន៍ពីសហគមន៍កសិកម្មនេះ ក៏ដូចជាលើកស្ទួយវិស័យកៅស៊ូឲ្យរីកចម្រើនផងដែរ។

បន្ទាប់មក លោកអភិបាលរង ស្រុកសំឡូត បានមានមតិស្វាគមន៍ចំពោះអង្គមហាសន្និបាតកំណើតដំបូងរបស់សហគមន៍កសិកម្មកៅស៊ូគ្រួសារស្រុកសំឡូត ដោយលោកបានថ្លែងអំណរគុណដល់ក្រុមការងារនៃអគ្គនាយកដ្ឋានកៅស៊ូ ដែលបានសហការជាមួយមន្ត្រីជំនាញនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង ក្នុងការចងក្រងជាសហគមន៍កសិកម្មកៅស៊ូគ្រួសារនេះឡើង។ លោកបានបន្ថែមទៀតថា នេះជា សហគមន៍កសិកម្មកៅស៊ូគ្រួសារទី១ហើយនៅក្នុងស្រុកសំឡូត ដែលកន្លងមកធ្លាប់មានតែសហគមន៍កសិកម្មចិញ្ចឹមសត្វ សន្សំប្រាក់ និងសហគមន៍កសិកម្មដាំដំណាំផ្សេងក្រៅពីដំណាំកៅស៊ូ។ ការបង្កើតសហគមន៍កសិកម្មដំណាំកៅស៊ូនេះ នឹងជួយ

ដល់កសិករដាំដុះដំណាំកៅស៊ូក្នុងការរកស៊ីរួមគ្នាជាក្រុមងាយស្រួលក្នុងការទិញ-លក់របស់កសិករ និងជួយពង្រឹងសមត្ថភាពកសិករកៅស៊ូគ្រួសារផងដែរ។




*គណៈអធិបតីអង្គមហាសន្និបាតកំណើតដំបូងរបស់សហគមន៍ស្រុកសំឡូត ខេត្តបាត់ដំបង*

ជាកិច្ចបន្ទាប់ លោកអគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ បានមានមតិបើកមហាសន្និបាតកំណើតដំបូងរបស់សហគមន៍កសិកម្មកៅស៊ូគ្រួសារស្រុកសំឡូតដោយលោកបានលើកឡើងថា នេះជាសហគមន៍កៅស៊ូគ្រួសារទី១នៅក្នុងខេត្តបាត់ដំបង និងជាសហគមន៍កៅស៊ូគ្រួសារទី៥នៅក្នុងប្រទេសកម្ពុជា។ លោកក៏បានបញ្ជាក់បន្ថែមទៀតថា ការបង្កើតសហគមន៍កសិកម្មកៅស៊ូគ្រួសារនេះ កសិករយើងនឹងទទួលបាននូវអត្ថប្រយោជន៍ជាច្រើនដូចជា៖

- ❖ ទទួលបានទីផ្សារនិងពង្រីកឱកាសទីផ្សារកសិផលរបស់កសិករ និងលើកកម្ពស់អំណាចចរចារថ្លៃផលិតផលលើទីផ្សារដែលកាត់បន្ថយការកេងប្រវ័ញ្ចរបស់ឈ្មួញកណ្តាល តាមរយៈការទិញលក់ធាតុចូលកសិកម្ម និងកសិផលរួមគ្នា
- ❖ លើកកម្ពស់គុណភាពកសិផលឬផលិតផល និងកាត់បន្ថយថ្លៃដើមផលិតកម្មកសិកម្មរបស់សមាជិកសហគមន៍ តាមរយៈការទិញសម្ភារឬឧបករណ៍កសិកម្មនៅមូលដ្ឋានរបស់គេ ព្រមទាំងធានាគុណភាពល្អ
- ❖ ផលិតកសិផល ឬផ្តល់សេវាកម្មណា ដែលកសិករម្នាក់ៗមិនអាចធ្វើបាន
- ❖ ផ្តល់សេវាឥណទានដល់សមាជិកក្នុងអត្រាការប្រាក់ទាបជាងឯកជន
- ❖ បង្កើនប្រាក់ចំណូលគ្រួសាររបស់សមាជិកសហគមន៍ តាមរយៈការទទួលបានប្រាក់ចំណេញពីមុខរបរជំនួញទៅតាមសមាមាត្រភាគហ៊ុនដែលបានដាក់
- ❖ បង្កើនចំណេះដឹង និងសមត្ថភាពលើផ្នែកបច្ចេកទេសកសិកម្ម ការធ្វើជំនួញ និងការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ
- ❖ មានការទទួលស្គាល់ និងទទួលបានការគាំទ្រលើកទឹកចិត្តពីរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធនានា។

ជាចុងក្រោយ លោកអគ្គនាយករង ក៏បានអរគុណដល់មន្រ្តីជំនាញនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង ដែលបានសហការក្នុងរៀបចំចងក្រងសហគមន៍នេះឡើង និងបានផ្តាំផ្ញើដល់ក្រុមប្រឹក្សាភិបាលសហគមន៍ គណៈកម្មាធិការត្រួតពិនិត្យ និងសមាជិកទាំងអស់ សហការគ្នាឲ្យបានល្អទុកចិត្តគ្នាទៅវិញទៅមកមានតម្លាភាព និងគណនេយ្យភាព ដើម្បីបម្រើផលប្រយោជន៍សហគមន៍ឲ្យមានភាពរីកចម្រើន ជាពិសេស ត្រូវពង្រឹងជំនាញ

ក្នុងការដឹកនាំនិងគ្រប់គ្រងសហគមន៍របស់ខ្លួនឲ្យមានដំណើរការទៅរលូនល្អនិងជោគជ័យ។

ជាលទ្ធផល មហាសន្និបាតបានធ្វើការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាភិបាលចំនួន ០៥រូប ក្នុងចំណោមបេក្ខជនឈរឈ្មោះចំនួន ០៧រូប និងជ្រើសតាំងគណៈកម្មាធិការត្រួតពិនិត្យចំនួន ០៣រូប ក្នុងចំណោមបេក្ខជនឈរឈ្មោះចំនួន ០៥រូប។

អង្គមហាសន្និបាត បានអនុម័តលើចំនុចសំខាន់ៗដូចខាងក្រោម ៖

១)-អនុម័តឈ្មោះសហគមន៍គឺ សហគមន៍កសិកម្មកៅស៊ូគ្រួសារស្រុកសំឡូត “ ស.ក.ក.គ.ស” ឈ្មោះជាភាសាអង់គ្លេស៖ Samlot Rubber Smallholding Agricultural Cooperative "S.R.S.A.C" អាស័យដ្ឋានសហគមន៍៖ ភូមិព្រៃរំចេក ឃុំតាសាញ ស្រុកសំឡូត ខេត្តបាត់ដំបង

២)-អនុម័តប្រតិបត្តិការមុខរបររបស់សហគមន៍មានដូចជា៖

**ក-ផលិតកម្មកសិកម្ម**

- ផលិតពូជកៅស៊ូ កូនកៅស៊ូ និងច្បារពូជកៅស៊ូ
- ផលិតទឹកជ័រកៅស៊ូ និងជ័រកកសម្រាប់ទីផ្សារ
- ផលិតកម្មកសិកម្ម (ម្រេច ពោត ធុរេន អង្ករ ស្វាយកែវរមៀត ស្វាយចន្ទី ចេក ដំឡូងមី សណ្តែក ល្ង មៀន សាវម៉ាវ រមៀត រំដេង ម្ទេស និងបន្លែគ្រប់មុខ)

**ខ-កសិឧស្សាហកម្ម**

- កែច្នៃជ័រកៅស៊ូសន្លឹក (RSS) និង
- កៅស៊ូដុំ (TSR) សម្រាប់ទីផ្សារ

**គ-កសិពាណិជ្ជកម្ម**

- ទិញ លក់ ទឹកជ័រ ជ័រកក ជ័រកៅស៊ូសន្លឹក (RSS) និងកៅស៊ូដុំ (TSR)
- ទិញ លក់ ផលិតផលកសិកម្ម
- ទិញ លក់ គ្រឿងឧបភោគ បរិភោគ
- លក់ប្រេងឥន្ធនៈ
- ផ្គត់ផ្គង់ធាតុចូលកសិកម្ម (ឧបករណ៍កសិកម្ម សម្ភារកសិកម្ម ជីកសិកម្ម ថ្នាំគីមីកសិកម្ម)

**ឃ-សេវាកម្មពាក់ព័ន្ធផលិតកម្មកសិកម្ម**

- ឥណទានសាច់ប្រាក់និងប្រាក់សន្សំ
- ប្រាក់បញ្ញើធនាគារ
- សេវាកម្មដឹកជញ្ជូន ភ្ជួររាស់

៣)-អនុម័តប្រាក់សមាជិកភាពត្រូវបង់ប្រចាំឆ្នាំ ចំនួន ២០ ០០០រៀល/នាក់/ឆ្នាំ

៤)-អនុម័តតម្លៃ ១ហ៊ុន ចំនួន ៥០ ០០០រៀល

៥)-អនុម័តការបែងចែកប្រាក់ចំណេញដូចជា៖

- មូលនិធិបម្រុងចំនួន ២០%
- មូលនិធិបណ្តុះបណ្តាលចំនួន ០៣%
- មូលនិធិសាងសង់ចំនួន ១០%
- ប្រាក់ភាគលាភសមាជិកចំនួន ៤០%
- មូលនិធិអភិវឌ្ឍន៍មុខជំនួញចំនួន ១៧%
- មូលនិធិលើកទឹកចិត្តថ្នាក់ដឹកនាំសហគមន៍ចំនួន ០៨%
- មូលនិធិសង្គមចំនួន ០២%

៦)-អនុម័តស្លាកសញ្ញាសំគាល់និងត្រារបស់សហគមន៍

៧)-អនុម័តលក្ខន្តិកៈសហគមន៍រួមមាន ១១ ជំពូក ៩៣ប្រការ និងបទបញ្ជាផ្ទៃក្នុងមាន ០៦ជំពូក និង ២១ប្រការ។



*ដំណើរការនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យសហគមន៍*

អង្គមហាសន្និបាតបានលើកដៃអនុម័តលើខ្លឹមសាររួមនៃលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍ ដោយសម្លេងជាឯកច្ឆ័ន្ទ។

ជាការផ្តាំផ្ញើដល់អង្គមហាសន្និបាត លោកបណ្ឌិត **អូន សុវណ្ណា** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ បានមានមតិបិទអង្គសន្និបាតដោយក្រើនរំឭកដល់ក្រុមប្រឹក្សាភិបាលនិងគណៈកម្មាធិការត្រួតពិនិត្យសហគមន៍ ដែលទើបទទួលបានការទុកចិត្តពីសមាជិកប្រគល់ភារកិច្ចឲ្យដឹកនាំសហគមន៍ ត្រូវប្រឹងប្រែងអស់ពីសមត្ថភាពក្នុងការបំពេញការងារ ដើម្បីសម្រេចនូវគោលដៅរបស់សហគមន៍ និងជំរុញផលិតភាពកសិកម្ម គុណភាពកសិផល ដើម្បីក្លាយជាដៃគូផ្គត់ផ្គង់កសិផលជាក់លាក់ទៅកេទីផ្សារ ស្របតាមទិសដៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏ដូចជា រាជរដ្ឋាភិបាលកម្ពុជា។

តាមរយៈការចងក្រងសហគមន៍កសិកម្មកៅស៊ូគ្រួសារស្រុកសំឡូត ខេត្តបាត់ដំបងបានបង្ហាញឱ្យឃើញថា កសិករកៅស៊ូគ្រួសារមានការចាប់អារម្មណ៍ក្នុងការបង្កើតសហគមន៍កសិកម្មកៅស៊ូគ្រួសារ និងចូលរួមពិភាក្សាយ៉ាងផុសផុលជាមួយមន្ត្រីជំនាញអគ្គនាយកដ្ឋានកៅស៊ូនិងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង ព្រមទាំង សំណូមពរដល់អគ្គនាយកដ្ឋានកៅស៊ូជួយសម្របសម្រួល ផ្តល់ជាគំនិតយោបល់និងជួយរៀបចំឯកសារពាក់ព័ន្ធនានាបន្តទៀត ដើម្បីអាចឲ្យសហគមន៍ ដែលទើបបង្កើតថ្មីនេះចុះបញ្ជីនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង បានដោយជោគជ័យនិងនៅតែបន្តជួយពង្រឹងសមត្ថភាពសហគមន៍នៅឆ្នាំក្រោយៗបន្ថែមទៀតផងដែរ។

## វគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS ដល់សហគមន៍កៅស៊ូគ្រួសារ

បច្ចុប្បន្នវិស័យកៅស៊ូនៅប្រទេសកម្ពុជា បានដើរតួនាទីសំខាន់ក្នុងការស្តារជីវភាពរស់នៅរបស់ប្រជាកសិករ ជាពិសេស ប្រជាកសិករដែលមានដីតិចតួចនៅតាមតំបន់ដាច់ស្រយាល ទាំងតំបន់ដីប្រពៃណី

និងមិនមែនប្រពៃណី។ ម្ចាស់ចម្ការកៅស៊ូគ្រួសារតូចតាចទាំងនោះ បានលក់ទឹកជ័ររបស់ខ្លួនផ្ទាល់ទៅឈ្មួញកណ្តាល និងម្ចាស់រោងចក្រសិប្បកម្មមួយចំនួន ដែលបណ្តាលឲ្យពួកគាត់បាត់បង់នូវផលប្រយោជន៍របស់ខ្លួន (១)គ្មានអំនាចក្នុងការចរចារថ្លៃ (២)ការបាត់បង់ DRC និងទម្ងន់។ល។

ដើម្បីដោះស្រាយបញ្ហាទាំងនេះ នាយកដ្ឋានកែច្នៃផលិតផលកៅស៊ូនៃអគ្គនាយកដ្ឋានកៅស៊ូ បានផ្តើមគំនិតបង្កើតនូវវគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS សំដៅជួយសម្រាលការលំបាករបស់ម្ចាស់កៅស៊ូគ្រួសារតូចតាចទាំងនោះ។

នៅពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្ថិតនៅឃុំស្រែអំពូមស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី មានបើកវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS ដល់កសិករម្ចាស់កៅស៊ូគ្រួសារមកពីបណ្តាភូមិ ក្នុងឃុំស្រែអំពូម ស្រុកពេជ្រាដា ចំនួន ៥០នាក់ ក្នុងគោលបំណង៖

- ❖ ផ្តល់បច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS ដល់ប្រជាកសិករនៅក្នុងសហគមន៍កៅស៊ូគ្រួសារ
- ❖ ជំរុញឲ្យមានការបង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូរួមនៅតាមមូលដ្ឋានរបស់កសិករទាំងនោះ។

លទ្ធផលរំពឹងទុកនៃវគ្គបណ្តុះបណ្តាលនេះ គឺកសិករម្ចាស់កៅស៊ូគ្រួសារ នឹងចេះកែច្នៃនិងលក់ដូរមានលក្ខណៈប្រមូលផ្តុំ (បំពាក់តម្លៃបន្ថែមនិងមានអំណាចចរចារថ្លៃ) និងទទួលបានប្រាក់ចំណូលជាអតិបរិមា។

វគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាល ត្រូវបានទទួលកិត្តិយសជាអធិបតីដោយលោក **ហ៊ឹម អួន** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ និងលោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី។



*លោក **ហ៊ឹម អួន** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ បានអញ្ជើញជាអធិបតីក្នុងវគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាល បច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS ដល់សហគមន៍កៅស៊ូគ្រួសារនៅខេត្តមណ្ឌលគិរី*

ជាកិច្ចស្វាគមន៍ លោក **សុខ ឃាង** ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី បានថ្លែងអំណរគុណដល់ក្រុមការងារ នៃអគ្គនាយកដ្ឋានកៅស៊ូ ដែលបានប្រារព្ធពិធីដ៏មានសារៈសំខាន់នេះ និងបានលើកឡើងពីអត្ថប្រយោជន៍នៃចំណេះដឹងទៅលើខ្សែចង្វាក់កែច្នៃជ័រកៅស៊ូ ទោះបីបច្ចុប្បន្នតម្លៃកៅស៊ូហាក់មានភាពល្អប្រសើរបន្តិច ក៏ពិតមែនតែបច្ចេកទេសនៃការកែច្នៃវាមានសារៈសំខាន់ណាស់ក្នុងការជួយបង្កើនតម្លៃបន្ថែម ដែលបច្ចុប្បន្នកសិករធ្វើការបង្កកទឹកជ័ររួច និងធ្វើការលក់តែម្តងដែលធ្វើឲ្យយើងបាត់បង់តម្លៃបន្ថែម។

ក្នុងមតិសំណេះសំណាលបើកវគ្គផ្សព្វផ្សាយ លោក **ហ៊ឹម អួន** អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ បានថ្លែងនូវអំណរគុណដល់អង្គភាពនិងអាជ្ញាធរ

ពាក់ព័ន្ធ ដែលបានសម្របសម្រួលឲ្យមានការប្រារព្ធពិធីនេះឡើង។ លើសពីនេះទៅទៀត លោកបានលើកឡើងពីគុណប្រយោជន៍ដំណាំកៅស៊ូជូនដល់វគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាលនេះដោយ (១)ផ្តល់នូវប្រាក់ចំណូលដល់សេដ្ឋកិច្ចកៅស៊ូគ្រួសារនិងសេដ្ឋកិច្ចជាតិ និងបានចូលរួមចំណែកកាត់បន្ថយភាពក្រីក្រនៅក្នុងតំបន់ (២)បង្កើតការងារនិងមុខរបរស្ថេរភាពជូនប្រជាពលរដ្ឋនៅក្នុងតំបន់ និងជួយកាត់បន្ថយការធ្វើចំណាកស្រុក (៣)ផ្តល់ឈើសម្រាប់ប្រើប្រាស់គ្រឿងសំណង់ សង្ហារឹម ជាឈើឥន្ធនៈ ដែលជួយកាត់បន្ថយការកាប់បំផ្លាញព្រៃធម្មជាតិ (៤)ការពារការហូរច្រោះដី និងការបង្កើតជាគម្របព្រៃបៃតងឡើងវិញ ដើម្បីជួយកាត់បន្ថយការប្រែប្រួលអាកាសធាតុដែលជាបញ្ហាចំបងនាពេលបច្ចុប្បន្ន និង (៥)តម្រូវការចាំបាច់សម្រាប់កម្មន្តសាលផលិតទំនិញឧស្សាហកម្មរាប់ពាន់មុខ។

ជាកិច្ចបន្ត មន្ត្រីជំនាញនៃនាយកដ្ឋានកែច្នៃផលិតផលកៅស៊ូ បានលើកនូវប្រធានបទសំខាន់ៗចំនួន២ មកធ្វើការផ្សព្វផ្សាយ៖

- ❖ បច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS
- ❖ បច្ចេកទេសបង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូ

ជាលទ្ធផល វគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាលបានបង្ហាញឃើញថា៖

- ❖ បន្ទាប់ពីស្ថានភាពតម្លៃ ជ័រកៅស៊ូមានភាពល្អប្រសើរបន្តិចឡើងវិញ ម្ចាស់កៅស៊ូគ្រួសារបានចូលរួមយ៉ាងផុសផុល និងយកចិត្តទុកដាក់យ៉ាងខ្លាំងចំពោះការបង្ហាញពី បច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក USS និងចាប់អារម្មណ៍ជាពិសេសលើការបង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូ
- ❖ ម្ចាស់កៅស៊ូគ្រួសារភាគច្រើន មានបំណងចង់បង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូ ប៉ុន្តែ គាត់មានការបារម្ភអំពីបញ្ហាតម្លៃ និងបញ្ហាទីផ្សារជ័រកៅស៊ូបន្ទាប់ពីគាត់បង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូ
- ❖ ម្ចាស់កៅស៊ូគ្រួសារ បានស្នើសុំការជួយណែនាំក្នុងការសាងសង់មណ្ឌលកែច្នៃ និងផ្តល់សេវាបច្ចេកទេសបន្ថែមពីអគ្គនាយកដ្ឋានកៅស៊ូ នៅពេលពួកគាត់មានលទ្ធភាពសាងសង់
- ❖ ម្ចាស់កៅស៊ូគ្រួសារបានស្នើសុំអគ្គនាយកដ្ឋានកៅស៊ូ ជួយផ្តល់នូវវគ្គបណ្តុះបណ្តាលពីបច្ចេកទេសផ្សេងៗទៀត ទាក់ទងនឹងដាំណាំកៅស៊ូ ជាពិសេស ជួយទំនាក់ទំនងរកទីផ្សារទិញផលិតផលកៅស៊ូ។

ជាកិច្ចបញ្ចប់លោក **ហ៊ឹម អួន** បានមានមតិថ្លែងអំណរគុណដល់មន្ត្រីពាក់ព័ន្ធទាំងអស់ និងបានផ្តល់នូវអនុសាសន៍ជូនដល់អ្នកចូលរួមទាំងអស់ ពិសេសកសិករម្ចាស់កៅស៊ូគ្រួសារដែលមានបំណងចង់បង្កើតមណ្ឌលកែច្នៃជ័រកៅស៊ូត្រូវ៖ (១)រៀបចំចងក្រងជាក្រុមឬសហគមន៍កៅស៊ូគ្រួសារដើម្បីទទួលបាននូវព័ត៌មានពាក់ព័ន្ធវិស័យកៅស៊ូ និង(២)ទំនាក់ទំនងមកអគ្គនាយកដ្ឋានកៅស៊ូ តាមរយៈអាជ្ញាធរពាក់ព័ន្ធដើម្បីទទួលយកនូវជំនួយបច្ចេកទេសពីអគ្គ-នាយកដ្ឋានកៅស៊ូ។



សកម្មភាពនៃវគ្គផ្សព្វផ្សាយនិងបណ្តុះបណ្តាល

## កិច្ចសហប្រតិបត្តិការរវាង អគ្គនាយកដ្ឋានកៅស៊ូ ជាមួយនឹងក្រុមហ៊ុន Anhui Easy Business

កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅអគ្គនាយកដ្ឋានកៅស៊ូ មានកិច្ចប្រជុំមួយជាមួយក្រុម Anhui Easy Business Digital Technology Co.,Ltd នៃប្រទេសចិន ក្រោមអធិបតីភាព លោក **ឃុន ភក្តា** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ និងមានវត្តមាន លោកប្រធាន អនុប្រធាននាយកដ្ឋានជំនាញ ព្រមទាំងលោកនាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា ក៏បានអញ្ជើញចូលរួមផងដែរ។ គោលបំណងនៃកិច្ចប្រជុំនេះ គឺដើម្បីចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមកនៃការគ្រប់គ្រងទិន្នន័យ និងព័ត៌មានអោយបានគ្រប់ជ្រុងជ្រោយប្រកបដោយប្រសិទ្ធភាពខ្ពស់ និងប្រមូលជាតុចូលនានាសម្រាប់បញ្ចូលក្នុងរបាយការណ៍សិក្សាលទ្ធភាពអាចធ្វើបានស្តីអំពី ”Soft Infrastructure of Agriculture for Quality Standard Inspection and SPS Cooperation Project Feasibility Study” ។



លោក **ឃុន ភក្តា** អគ្គនាយករង នៃអគ្គនាយកដ្ឋានកៅស៊ូ ក្នុងកិច្ចប្រជុំជាមួយក្រុមហ៊ុនចិន Easy's Biz

ជាកិច្ចចាប់ផ្តើមលោក **ឃុន ភក្តា** បានមានមតិស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានក្រុមហ៊ុនចិននិងអ្នកដែលបានចូលរួមក្នុងកិច្ចពិភាក្សានេះ។ ជាមួយគ្នានោះ លោកក៏បានលើកឡើងអំពីតួនាទីរចនាសម្ព័ន្ធរបស់អគ្គនាយដ្ឋានកៅស៊ូ ផលិតកម្មកៅស៊ូ ស្ថិតិ នៃការនាំចេញកៅស៊ូ ព្រមទាំងការចេញវិញ្ញាបនបត្រសម្រាប់ការនាំចេញកៅស៊ូ ផ្តល់អោយនូវព័ត៌មានពីការសិក្សាលទ្ធភាពនៃតម្លៃកៅស៊ូ ដូចជារបាយការណ៍ប្រចាំឆ្នាំស្តីពីកៅស៊ូ និងអនុក្រឹតមួយចំនួនដែលពាក់ព័ន្ធនឹងវិស័យកៅស៊ូជាដើម។

ក្រុមហ៊ុន Anhui Easy Business ក៏បានធ្វើបទបង្ហាញអំពីព័ត៌មានគម្រោងរបស់ខ្លួន រួមមានប្រវត្តិបង្កើតគម្រោង និងជាតុចូលសំខាន់ៗសម្រាប់បង្កើតគម្រោង។

បន្ទាប់មក លោកនាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា បានលើកឡើងពីការធ្វើតេសកៅស៊ូ នីតិវិធីនៃការចេញ វិញ្ញាបនបត្រកៅស៊ូ និងបញ្ហានាពេលបច្ចុប្បន្នគឺមិនមានឧបករណ៍គ្រប់គ្រាន់សម្រាប់

ធ្វើការត្រួតពិនិត្យលើការធ្វើតេសសំណាកកៅស៊ូ ម្យ៉ាងវិញទៀត ការយល់ដឹងនូវមានកំរិតទាក់ទងទៅនឹងផ្នែកគុណភាព និងស្តង់ដានីតិវិធីនាំចេញកៅស៊ូជាដើម។

ក្រោយមក តំណាងនាយកដ្ឋាននីមួយៗបានបំភ្លឺនិងលើកសំណូមពរពីគម្រោងមួយចំនួនជូនភាគីចិនដាក់បញ្ចូលក្នុងរបាយការណ៍។

ជាលទ្ធផលក្រោយពីបានធ្វើការពិភាក្សារួចមក អគ្គនាយកដ្ឋានកៅស៊ូ និងក្រុមហ៊ុន Anhui Easy Business បានឯកភាពគ្នាលើចំណុចរួមដូចខាងក្រោម៖

១. អគ្គនាយកដ្ឋានកៅស៊ូ មានតម្រូវការចាំបាច់ ត្រូវការបង្កើតប្រព័ន្ធគ្រប់គ្រងប្រតិបត្តិករកៅស៊ូអោយបានកាន់តែប្រសើរ ដើម្បីតាមដានលើដំណើរការកែច្នៃ និងការនាំចេញកៅស៊ូឲ្យមានប្រសិទ្ធភាពខ្ពស់

២. អគ្គនាយកដ្ឋានកៅស៊ូ ត្រូវការអោយមានការ ប្រើប្រាស់ប្រព័ន្ធ Online សម្រាប់គ្រប់គ្រង និងផ្តល់វិញ្ញាបនបត្របញ្ជាក់គុណភាពកៅស៊ូ ដើម្បីធានាគុណភាព នឹងសម្រួលដល់ការនាំចេញកៅស៊ូ

៣. អគ្គនាយកដ្ឋានកៅស៊ូ សូមអោយមានការពង្រឹងសមត្ថភាព និងការបង្កើតស្តង់ដារលើការត្រួតពិនិត្យផលិតផលកៅស៊ូ ដើម្បីរក្សាគុណភាពផលិតផលកៅស៊ូរបស់កម្ពុជាឲ្យមានការទទួលស្គាល់ជាអន្តរជាតិ

៤. អគ្គនាយកដ្ឋានកៅស៊ូ រំពឹងថានឹងទទួលបានព័ត៌មាន និងទំនាក់ទំនងពាណិជ្ជកម្មច្រើនឡើងរវាងប្រទេសចិននិងកម្ពុជា សម្រាប់បង្កើនតម្លៃបន្ថែមលើការនាំចេញទៅកាន់ប្រទេសចិន

៥. អគ្គនាយកដ្ឋានកៅស៊ូ និងក្រុមហ៊ុន Easy Biz បានឯកភាពគ្នានឹងធ្វើការសិក្សាលម្អិត និងផ្តល់ព័ត៌មានថ្មីៗបន្ថែមជាបន្តបន្ទាប់ នៅពេលក្រោយៗទៀត។

ជាមួយគ្នានេះដែរ ភាគីចិនបានដាក់បញ្ចូលគម្រោងចំនួន ៦ ទៅក្នុងរបាយការណ៍នេះរួមមាន៖

- Rubber Testing Standard Management System
- Rubber Operation and Management System
- GIS Rubber Plantation Management System
- Rubber Laboratory Management System
- Rubber Resources Statistic and Analysis System
- Rubber Quality Certificate Management System



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកៅស៊ូ**

លេខ: ១០៨០ អក.ទន

**សូមគោរពជូន**

**ឯកឧត្តម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ** ៖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែ១១ ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត។
**ជូនភ្ជាប់** ៖ របាយការណ៍ស្តីពីស្ថានភាពការងារអគ្គនាយកដ្ឋានកៅស៊ូប្រចាំខែ១១ ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត។

សេចក្តីមានចែងក្នុងកម្មវត្ថុ និងជូនភ្ជាប់ដូចខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលជ្រាបអំពីលទ្ធផលការងារសម្រេចបាន របស់អគ្គនាយកដ្ឋានកៅស៊ូប្រចាំខែ១១ ឆ្នាំ២០១៧ ដោយសង្ខេបដូចខាងក្រោម៖

១.ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤៣៩ ៧៩៧ ហិកតា ដែលក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ១៧០ ៣៣៧ ហិកតា ស្មើនឹង ៣៨,៧៣% និងផ្ទៃដីថែទាំមានចំនួន ២៦៩ ៤៥៩ ហិកតា ស្មើនឹង៦១,២៦% ។

២.បរិមាណផលិតផលសម្រេចបានចំនួន ១៥៩ ៨០៥ តោន បានកើនឡើង ចំនួន ៤២ ៦៨២ តោន ស្មើនឹង៣៦% បើធៀបរយៈពេលដូចគ្នាទៅនឹងឆ្នាំមុន។

៣.បរិមាណបញ្ចេញលក់មានចំនួន ១៥២ ៩៦២ តោន បានកើនឡើងចំនួន ៣៦ ៦១៣ តោន ស្មើនឹង៣១% បើធៀបរយៈពេលដូចគ្នាទៅនឹងឆ្នាំមុន ។

៤.តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងរយៈពេល១១ខែគឺ ១ ៦២៥ ដុល្លារ/តោន បានកើនឡើង ៤៥២ ដុល្លារ/តោន ស្មើនឹង៣៨% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

៥.ទិសដៅបន្ត៖

- ប្រជុំរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងលិខិតបទដ្ឋានក្រោមច្បាប់នានា
- ចុះអនុវត្តសកម្មភាពគម្រោងតាមកម្មវិធីឱ្យបានសម្រេចតាមផែនការដែលបានគ្រោងទុក
- ចុះសិក្សាទិន្នផលកៅស៊ូគ្រួសាររបស់គម្រោងធម្មយាមកម្មច្បារពូជនៅកម្ពុជា
- ចុះត្រួតពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច និងជំរុញការប្រមូលចំណូលចូលថវិការដ្ឋតាមការគ្រោងទុក
- ផ្សព្វផ្សាយតម្លៃកៅស៊ូតាមវិទ្យុ លើគេហទំព័រហ្វេសប៊ុក និងព្រឹត្តប័ត្ររបស់អគ្គនាយកដ្ឋានកៅស៊ូ។

រីឯខ្លឹមសារលម្អិតដូចមានក្នុងរបាយការណ៍ជូនភ្ជាប់។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ ខ្ញុំបាទសូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យនិងជូនជ្រាបជារបាយការណ៍ដោយអនុគ្រោះ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ.ថ្ងៃច័ន្ទ ៨រោច ខែមិគសិរ ឆ្នាំរកា ព.ស២៥៦១
ថ្ងៃទី ១១ ខែ ធ្នូ គ.ស២០១៧

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**អគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**ប៉ុល សុផា**

**ចម្លងជូន៖**
- ឯកឧត្តមរដ្ឋលេខាធិការទទួលបន្ទុក.
- ឯកឧត្តមអនុរដ្ឋលេខាធិការទទួលបន្ទុក.
  " ដើម្បីជូនជ្រាប "
- នាយកដ្ឋានកិច្ចការរដ្ឋបាល កសក.
- នាយកដ្ឋានផែនការ និងស្ថិតិ កសក.
- នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃ អនក.
- គ្រប់ចម្ការកៅស៊ូកសិ-ឧស្សាហកម្ម.
  " ដើម្បីជ្រាប "
- ឯកសារ

ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
National Road No.6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៦៧២២ ៥៩០
Phone: (855) 23 6722 590, Email: gdr.maff@gmail.com

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានកៅស៊ូ

# របាយការណ៍
# ស្តីពី
# ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧ និងទិសដៅអនុវត្តបន្ត

## ១.សេចក្តីផ្តើម

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧នេះ ស្ថានភាពការងាររបស់អគ្គនាយកដ្ឋានកៅស៊ូ ទាំងការងារចរន្ត ការងារអនុវត្តគម្រោងតាមកម្មវិធី និងការងារផ្សេងៗទៀត បានដំណើរការជាធម្មតា។ ទន្ទឹមនឹងនេះ ការងារដាំដុះ ថែទាំកូនកៅស៊ូថ្មី ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ច ទាំងកៅស៊ូគ្រួសារ និងកៅស៊ូកសិឧស្សាហកម្ម មានសកម្មភាពផុលផុសឡើងវិញគួរឲ្យកត់សម្គាល់។ កត្តាវិជ្ជមានទាំងនេះ គឺអាស្រ័យដោយតម្លៃកៅស៊ូធម្មជាតិបានងើបឡើងបន្តិចវិញចាប់ពីខែមិថុនា ឆ្នាំ២០១៧រហូតមក គួបផ្សំនឹងស្ថានភាពរបាយទឹកភ្លៀងបានធ្លាក់រាយប៉ាយបានល្អស្មើតែគ្រប់បណ្តាខេត្តផងដែរ។ លទ្ធផលការងារសំខាន់ៗដែលអគ្គនាយកដ្ឋានកៅស៊ូសម្រេចបានក្នុងខែវិច្ឆិកាឆ្នាំ២០១៧ មានខ្លឹមសារលម្អិតជូនដូចខាងក្រោម៖

## ២.លទ្ធផលការងារសម្រេចបាន

### ២.១ ការងារអាជីវកម្ម ផលិតកម្ម និងធុរកិច្ចកៅស៊ូ

#### ២.១.១ ផ្ទៃដីកៅស៊ូ

ផ្ទៃដីកៅស៊ូសរុបមានចំនួន ៤៣៩ ៧៩៧ ហិកតា ដែលក្នុងនោះ៖ ផ្ទៃដីចៀរជ័រមានចំនួន ១៧០ ៣៣៧ ហិកតា ស្មើនឹង ៣៨,៧៣% និងផ្ទៃដីថែទាំមានចំនួន ២៦៩ ៤៥៩ ហិកតា ស្មើនឹង ៦១,២៦%។ ទំហំផ្ទៃដីក្នុងខែវិច្ឆិកានេះ កើនឡើងចំនួន ៨ ៤១៨ហត ស្មើនឹង ២%បើប្រៀបធៀបនឹងខែតុលា ឆ្នាំ២០១៧។

#### ២.១.២ ផលិតកម្ម

ផលិតផលជ័រកៅស៊ូសរុបសម្រេចបានក្នុងរយៈពេល១១មានចំនួន ១៥៩ ៨០៥ តោន បានកើនឡើង ចំនួន ៤២ ៦៨២ តោន ស្មើនឹង៣៦% បើធៀបរយៈពេលដូចគ្នាទៅនឹងឆ្នាំមុន។ ផលិតផលក្នុងខែវិច្ឆិកាសម្រេចបាន ចំនួន ២៣ ០២៨ តោន បានកើនឡើងចំនួន ៤ ៩៧៧ តោន ស្មើនឹង២៨% ធៀបនឹងខែតុលា ឆ្នាំ២០១៧ និងបានកើនឡើងចំនួន ៦ ០១២ តោន ស្មើនឹង ៣៥% ធៀបនឹងខែវិច្ឆិកា ឆ្នាំ២០១៦ ។

#### ២.១.៣ ធុរកិច្ចកៅស៊ូ

បរិមាណបញ្ចេញលក់ជ័រកៅស៊ូសរុបសម្រេចបានក្នុងរយៈពេល១១ខែមានចំនួន ១៥២ ៩៦២ តោន បានកើនឡើងចំនួន ៣៦ ៦១៣ តោន ស្មើនឹង៣១% បើធៀបរយៈពេលដូចគ្នាទៅនឹងឆ្នាំមុន ។ បរិមាណបញ្ចេញលក់ក្នុងខែ

អាស័យដ្ឋានៈ ផ្លូវជាតិលេខ៦អា ភូមិបាក់ខែង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ កម្ពុជា
Address: National Road No.6A, Phum Bakkheng, Sangkat Prek Leap, Khan Chroy Changva, Phnom Penh
ទូរស័ព្ទលេខៈ (៨៥៥) ២៣ ៦៧២២ ៥៩០
Phone: (855) 23 6722 590, Email:gdr.maff@gmail.com

វិច្ឆិកាចំនួន ២២ ១៤៦ តោន បានកើនឡើងចំនួន ៦ ៣៩១ តោន ស្មើនឹង៤១% ធៀបនឹងខែតុលា ឆ្នាំ២០១៧ និង បានកើនឡើងចំនួន ៥ ៦៥៤ តោន ស្មើនឹង៣៤% ធៀបនឹងខែវិច្ឆិកា ឆ្នាំ២០១៦ ។

តម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងរយៈពេល១១ខែគឺ ១ ៦២៥ ដុល្លារ/តោន បានកើនឡើង ៤៥២ ដុល្លារ/តោន ស្មើនឹង៣៨% បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

តម្លៃលក់មធ្យមប្រចាំខែគឺ១៤៥៩ ដុល្លារ/តោន បានថយចុះចំនួន ៦៣ ដុល្លារ/តោន ស្មើនឹង ៤,១២% ធៀបនឹងខែតុលា ឆ្នាំ២០១៧ នឹងបានថយចុះចំនួន ២៩ ដុល្លារ/តោន ស្មើនឹង ២% ធៀបនឹងខែវិច្ឆិកា ឆ្នាំ២០១៦ ។

## ២.២. ការងារបច្ចេកទេស និងការអនុវត្តគម្រោងតាមកម្មវិធី

### ២.២.១. ការងារបច្ចេក

- បានប្រជុំរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូនិងលិខិតបទដ្ឋាននានាក្រោមច្បាប់បានចំនួន២ លើកនៅអគ្គនាយកដ្ឋានកៅស៊ូ
- បានចុះបើកវគ្គផ្សព្វផ្សាយដើម្បីចងក្រងសហគមន៍កៅស៊ូគ្រួសារនៅខេត្ត បាត់ដំបង ប៉ៃលិន និង ខេត្តរតនគីរី
- បានចុះពិនិត្យ និងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដែលបាន ដាំដុះកៅស៊ូ នៅខេត្តរតនគីរី
- បានចុះសិក្សាលក្ខណសម្បត្ត(Profile)ចម្ការកៅស៊ូគ្រួសារបានចំនួន៤ខេត្ត គឺខេត្តស្ទឹងត្រែង រតនគីរី ក្រចេះ និងខេត្តត្បូងឃ្មុំ
- បើកវគ្គសិក្ខាសាលាផ្ទេរបច្ចេកវិទ្យាដំណាំកៅស៊ូ ដល់មន្ត្រីបង្គោលនៅសណ្ឋាគារភ្នំប្រុសខេត្តកំពង់ចាម
- បានចុះពិនិត្យនិងវាយតម្លៃបច្ចេកទេសដំណាំកៅស៊ូរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដែលបាន ដាំដុះកៅស៊ូនៅខេត្តឧត្តរមានជ័យនិងខេត្តសៀមរាប
- ចុះសិក្សាទិន្នផលកៅស៊ូគ្រួសាររបស់គម្រោងធម្មយាមកម្មច្បាររពូជនៅកម្ពុជា
- ប្រជុំរៀបចំបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឧស្សាហកម្មកៅស៊ូធម្មជាតិនៅកម្ពុជា(២០១៦-២០២៥)
- បានចុះផ្សព្វផ្សាយ និងបណ្តុះបណ្តាលបច្ចេកទេសកែច្នៃជ័រកៅស៊ូសន្លឹក ដល់សហគមន៍កៅស៊ូ គ្រួសារចំនួន០១លើកនៅក្រុងស្ទឹងត្រែង ខេត្តស្ទឹងត្រែង
- បានសិក្សាស្រាវជ្រាវប្រមូលទិន្នន័យនិងព័ត៌មានកៅស៊ូសម្រាប់រៀបចំព្រឹត្តប័ត្រប្រចាំខែ និងផ្សព្វផ្សាយតម្លៃកៅស៊ូធម្មជាតិលើគេហទំព័រហ្វេសប៊ុករបស់អគ្គនាយកដ្ឋានកៅស៊ូ
- បានប្រមូលទិន្នន័យនិងរៀបចំតម្លៃកៅស៊ូធម្មជាតិ សម្រាប់ផ្សាយប្រចាំសប្តាហ៍តាមវិទ្យុមណ្ឌល ព័ត៌មាន ស្ត្រីកម្ពុជា(FM102)ចំនួន៤ដង
- បានធ្វើតេស្តភាគសំណាកយថាប្រភេទ សម្រាប់ធ្វើតេស្តគុណភាពកែច្នៃរបស់រោងចក្រនៃគម្រោង AFD និងវិភាគសំណាកនៃក្រុមហ៊ុន ស៊ីហ្វូ វ៉ាប់ប៊ើរ លីមិតធីត
- បានអនុវត្តការងារបច្ចេកទេសតាមប្រព័ន្ធគ្រប់គ្រង ISO 17025 : 2005 របស់មន្ទីរពិសោធន៍ ដូចជា សរុបលទ្ធផលនៃការធ្វើតេស្តតាមគម្រោងរបស់ភាគីបារាំង (AFD) ការធ្វើព្យាសកម្មឧបករណ៍ពិសោធន៍ តាមបទដ្ឋាន ISO រៀបចំរបាយការណ៍លទ្ធផលចុះត្រួតពិនិត្យ វាយតម្លៃរោងចក្រកែច្នៃកៅស៊ូ CSR នៃក្រុមហ៊ុន ស៊ីហ្វូ វ៉ាប់ប៊ើរ លីមិតធីត ធ្វើតេស្តRound Rodinនិងការធ្វើតេស្តប្រៀបធៀបក្នុងស្រុក និងឯកសារបណ្តុះបណ្តាលបន្ថែមដល់មន្ត្រីមន្ទីរពិសោធន៍តាមប្រព័ន្ធ ISO។

**២.២.២. ការចំណាយថវិកាតាមគម្រោងកម្មវិធី**

រហូតដល់ក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ (រយៈពេលដប់មួយខែ) នាយកដ្ឋានជំនាញទាំង៥នៃអគ្គនាយកដ្ឋានកៅស៊ូ បានចំណាយថវិកាសរុបអស់ចំនួន ១ ៥១៧ ២៤១ ៦៥៣ រៀល សម្រាប់ចុះអនុវត្តសកម្មភាពគម្រោងតាមកម្មវិធី ។ ដោយឡែក ការអនុវត្តសកម្មភាពក្នុងខែវិច្ឆិកា ចំណាយអស់ថវិកាសរុបចំនួន ២៨២ ៩៩៩ ៨០០ រៀល។

**២.២.៣. ការប្រមូលចំណូលថវិកា**

រយៈពេល១១ខែ ឆ្នាំ២០១៧ ការប្រមូលចំណូលថវិកាសរុបបានចំនួន ១ ១៩៨ ១៣៤ ៦៧៤ រៀល ថ្លៃឈ្នួលដីរបស់ក្រុមហ៊ុនចម្ការកៅស៊ូចម្ការអណ្តូង មេមត់ ជុប ក្រែក ក្រុមហ៊ុននីហរីណរអាហរីណកៅស៊ូ ( និងប្រាក់ពិន័យក្រុមហ៊ុនចម្ការកៅស៊ូស្នួល ចម្ការអណ្តូង ពាមជាំង ឆ្នាំ២០១៦)។ ដោយឡែកក្នុងខែវិច្ឆិកានេះការប្រមូលចំណូលគ្មាន។

**៣. ទិសដៅបន្ត**

- បន្តប្រជុំរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកៅស៊ូ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នានា
- ត្រៀមរៀបចំសិក្ខាសាលាស្តីពីការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងការទប់ស្កាត់ការនាំជ័រ និងឈើកៅស៊ូមិនទាន់កែច្នៃទៅបរទេសនៅចុងខែវិច្ឆិកាខាងមុខនេះនៅសាលាខេត្តត្បូងឃ្មុំ
- បន្តចុះអនុវត្តសកម្មភាពគម្រោងតាមកម្មវិធីឱ្យបានសម្រេចតាមផែនការដែលបានគ្រោងទុក
- បន្តចុះត្រួតពិនិត្យវាយតម្លៃបច្ចេកទេសកៅស៊ូ របស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចដំណាក់កាលទី២
- បន្តចុះសិក្សាទិន្នផលកៅស៊ូគ្រួសាររបស់គម្រោងធម្មយាមកម្មច្បារពូជនៅកម្ពុជា
- បន្តស្រាវជ្រាវនិងប្រមូលទិន្នន័យកៅស៊ូក្នុងស្រុក និងអន្តរជាតិសម្រាប់រៀបចំព្រឹត្តិប័ត្រប្រចាំខែ និងផ្សព្វផ្សាយតម្លៃកៅស៊ូធម្មជាតិតាមវិទ្យុប្រចាំសប្តាហ៍ និងលើគេហទំព័រហ្វេសប៊ុករបស់អគ្គនាយកដ្ឋានកៅស៊ូ។

រាជធានីភ្នំពេញ ថ្ងៃច័ន្ទ ៨រោច ខែមិគសិរ ឆ្នាំរកា ព.ស២៥៦១

ថ្ងៃទី ១១ ខែ ធ្នូ គ.ស២០១៧

**ប្រធាននាយកដ្ឋាន រដ្ឋបាលនិងនិតិកម្ម**

ឃួន_ផល្លា

**បានឃើញ និងពិនិត្យត្រឹមត្រូវ**

**ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ**

**អគ្គនាយករង**

សេក_គន្ធី

អគ្គនាយកដ្ឋានកៅស៊ូ
នាយកដ្ឋានរដ្ឋបាល និងនីតិកម្ម

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## ស្ថានភាពផលិតកម្មកៅស៊ូប្រចាំខែវិច្ឆិកា ឆ្នាំ២០១៧

តារាងទី១

| ល.រ | ចម្ការកៅស៊ូ | ផ្ទៃដី(ហិកតា) | | | ឆ្នាំ២០១៦ | | | | សន្និធិដើមឆ្នាំ | ឆ្នាំ២០១៧ | | | | | ប្រៀបធៀប | | | | | | | | | | | | | | សន្និធិ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ផលិតផល(តោន) | | បញ្ចេញលក់(តោន) | | | ផលិតផល(តោន) | | | បញ្ចេញលក់(តោន) | | ខែមុន | | | | | | រយៈពេលដូចគ្នាឆ្នាំមុន | | | | | | | | |
| | | ចៀរជ័រ | ថែទាំ | សរុប | ខែនេះ | ដល់ខែនេះ | ខែនេះ | ដល់ខែនេះ | | ខែនេះ | ដល់ខែនេះ | សរុប | ខែនេះ | ដល់ខែនេះ | ផ្ទៃដីសរុប | | ផលិតផល | | បញ្ចេញលក់ | | ផលិតផល | | | | បញ្ចេញលក់ | | | | |
| | | | | | | | | | | | | | | | | | | | | | ខែនេះ | | ដល់ខែនេះ | | ខែនេះ | | ដល់ខែនេះ | | |
| | | | | | | | | | | | | | | | ហិកតា | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | តោន | % | |
| | I. កៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ក | ចម្ការកៅស៊ូកសិឧស្សាហកម្ម | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 1 | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | 583 | 194 | **776** | 68 | 577 | | 500 | 5 | 66 | 530 | **534** | 50 | **450** | 0 | 0 | **15** | 29 | 0 | 0 | -2 | -3 | -47 | -8 | 50 | 100 | -50 | -10 | 84 |
| 2 | ក្រុមហ៊ុនសុភក្តិនីកា អ៊ីនវេសមេន គ្រុប | 11.910 | 3.132 | **15.042** | 1.631 | 13.676 | 1.709 | 14.709 | 815 | 1.707 | 15.712 | **16.527** | 1.149 | **14.541** | -100 | -1 | **419** | 33 | 553 | 93 | 76 | 5 | 2.037 | 15 | -560 | -33 | -168 | -1 | 1.987 |
| 3 | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | 974 | 1.161 | **2.135** | 157 | 1.071 | 168 | 1.060 | 20 | 188 | 1.340 | **1.361** | 126 | **1.218** | 0 | 0 | **10** | 5 | 0 | 0 | 30 | 19 | 269 | 25 | -42 | -25 | 158 | 15 | 143 |
| 4 | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ ខូអិលធីឌី | 4.131 | 4.536 | **8.667** | 354 | 2.753 | 301 | 2.838 | 299 | 442 | 3.690 | **3.989** | 278 | **3.382** | 0 | 0 | **53** | 14 | 38 | 16 | 89 | 25 | 937 | 34 | -23 | -8 | 543 | 19 | 607 |
| 5 | ក្រុមហ៊ុនស៊ីហ្វ វ៉ាប់បើ លីមីតធីត(រតនគិរី) | 79 | 2.588 | **2.666** | 16 | 81 | | 110 | 44 | 155 | 523 | **567** | | **220** | 109 | 4 | **1** | 1 | -89 | 0 | 139 | 847 | 442 | 543 | 0 | 0 | 110 | 100 | 346 |
| 6 | ក្រុមហ៊ុនស៊ីហ្វ រីសសស់ លីមីធីត(ស្នួល) | 2.921 | 1.486 | **4.406** | 348 | 1.704 | 200 | 1.378 | 757 | 484 | 2.912 | **3.669** | 177 | **1.503** | 0 | 0 | **173** | 55 | 38 | 28 | 136 | 39 | 1.208 | 71 | -23 | -12 | 125 | 9 | 2.166 |
| 7 | ក្រុមហ៊ុនឡុងស្រេងអ៊ិនធើណេស៊ិនណល | 4.402 | 1.537 | **5.939** | 398 | 3.567 | 394 | 3.514 | 238 | 548 | 4.317 | **4.555** | 895 | **4.314** | 0 | 0 | **54** | 11 | 595 | 198 | 150 | 38 | 750 | 21 | 501 | 127 | 800 | 23 | 241 |
| 8 | ក្រុមហ៊ុនអានម៉ានី គ្រុប(ចម្ការអណ្តូង) | 3.327 | 2.597 | **5.924** | 249 | 1.645 | 125 | 1.584 | 160 | 356 | 2.649 | **2.809** | 370 | **2.625** | 569 | 11 | **13** | 4 | 98 | 36 | 106 | 43 | 1.004 | 61 | 245 | 196 | 1.041 | 66 | 184 |
| 9 | ក្រុមហ៊ុនអានម៉ានី គ្រុប(ពាមជាំង+រមាសហែក) | 1.882 | 1.242 | **3.124** | 125 | 855 | 75 | 826 | 134 | 144 | 1.286 | **1.420** | 130 | **1.330** | -266 | -8 | **-2** | -2 | -13 | -9 | 19 | 15 | 432 | 51 | 55 | 73 | 504 | 61 | 90 |
| 10 | ក្រុមហ៊ុនក្រែក(ខេមបូឌា) ខូអិលធីឌី | 4.135 | 664 | **4.798** | 452 | 3.759 | 578 | 4.210 | 300 | 538 | 4.845 | **5.144** | 1.071 | **4.679** | 0 | 0 | **42** | 8 | 1.071 | 100 | 86 | 19 | 1.086 | 29 | 493 | 85 | 469 | 11 | 465 |
